# ព្រឹត្តិបត្រព័ត៌មាន

# អំពីស្ត្រី



ជំរុញសមភាពយេនឌ័រក្នុងសង្គមមួយ ដែលស្ត្រីអាចប្រើប្រាស់សិទ្ធិរបស់ខ្លួនមានគុណភាព និងអាចកសាងសមត្ថភាពដើម្បីក្លាយជាអ្នកមានភាពម្ចាស់ការ
http://women.open.org.kh

ឆ្នាំទី ៖ ០១ លេខ ៖ ០០២ ចេញផ្សាយសម្រាប់ខែមេសា ឆ្នាំ២០១០


## បទវិចារណកថា

### ស្ត្រីកម្ពុជានិងតម្រូវការចំណេះដឹងផ្នែកបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា(ICT)

បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ICT មានពាក្យពេញជាភាសាអង់គ្លេសថា Information Communication Technology គឺជាបច្ចេកវិទ្យាថ្មីមួយ ដែលគេទើបបានយកមកប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា ក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៩០។ បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា មានន័យយ៉ាងទូលាយ ដោយសំដៅទៅលើឧបករណ៍ និងទម្រង់ ដែលយើងប្រើប្រាស់សម្រាប់បំពេញតម្រូវការទំនាក់ទំនង និងព័ត៌មាន ឧទាហរណ៍ដូចជា វិទ្យុ ទូរស័ព្ទ ទូរទស្សន៍ និងអ៊ីនធឺណិត។ ICT បានក្លាយទៅជាឧបករណ៍មួយដ៏សំខាន់សម្រាប់ការទំនាក់ទំនងជាបណ្ដាញ រវាងអង្គការមួយទៅអង្គការមួយ រវាងស្ថាប័នមួយទៅស្ថាប័នមួយ។ នាពេលបច្ចុប្បន្ននេះ ICT គឺជាគុផ្សំដ៏ចាំបាច់មួយ សម្រាប់ទំនាក់ទំនងរវាងមនុស្ស និងមនុស្ស ដោយគ្មានព្រំដែន

(តទៅទំព័រទី ២)

## មាតិកា


- អនុសញ្ញាស្ដីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ ទំព័រទី៣
- ស្ត្រីកម្ពុជាទទួលផលប្រយោជន៍ពីបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ទំព័រទី៥
- ស្ត្រីមានផ្ទៃពោះគួរយល់ដឹងពីការប្រើកុំព្យូទ័រ ទំព័រទី៧
- ស្វែងយល់ពីការប្រើប្រាស់យូនីកូដខ្មែរ ទំព័រទី៧


## សង្គម និងការអភិវឌ្ឍន៍



សមាជិកកិច្ចប្រជុំវេទិកាស្ត្រីកំពុងចុះហត្ថលេខា "និយាយថាទេចំពោះអំពើហិង្សាលើស្ត្រី"
រូបភាពដោយ៖ អង្គការវិទ្យាស្ថានបើកទូលាយ

### ស្ត្រី និងឱកាសការងារក្នុងប្រព័ន្ធ ICT

ខណៈដែលវិទ្យាសាស្ត្រកាន់តែរីកចម្រើននៅក្នុងដំណាក់កាលនៃសកលភាវូបនីយកម្ម នោះបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ដែលភាសាអង់គ្លេសហៅថា Information Communication Technology (ICT) ក៏កាន់តែរីកលូតលាស់ដែរ ដែលតម្រូវឲ្យមនុស្សស្រីប្រុសទទួលយកការវិវត្តនេះសម្រាប់យកទៅប្រកបរបរចិញ្ចឹមជីវិត ជួយលើកស្ទួយ

(តទៅទំព័រទី ៦)

## ទេពកោសល្យស្ត្រី និងបុរស

### ទូរស័ព្ទដៃជួយសម្រួលមុខរបរបានប្រសើរជាងមុន

មិនដូចកាលពី ៩ឆ្នាំមុននោះទេ មុខរបរខ្នាតតូចរបស់ស្ត្រីម្នាក់មើលទៅដូចជាមានសកម្មភាពមមាញឹកជាងមុន។

រស់នៅក្នុងភូមិកំពង់កែស ឃុំត្រពាំងសង្កែ ស្រុកទឹកឈូ ខេត្តកំពត ដែលមានចម្ងាយប្រហែលជា ៧គីឡូម៉ែត្រពីក្រុងកំពត អ្នកស្រី ផាន់ណា បានខិតខំតស៊ូនៅក្នុងជីវិតជាមួយនឹងស្វាមី ប្រកបរបរសុចរិត ដើម្បីរស់នៅក្នុងសង្គមមួយប្រកបដោយសេចក្ដីថ្លៃថ្នូរ។

ស្ថិតក្នុងវ័យ ៣២ឆ្នាំ អ្នកស្រីមានកូនតូចៗចំនួន ៤នាក់នៅក្នុងបន្ទុក។ សព្វថ្ងៃនេះ អ្នកស្រីលក់គ្រឿងទេស (ចាប់ហួយ) នៅឯផ្ទះរបស់ខ្លួន។ ផ្ដើមចេញពីចំណុចតូចមួយនៅឆ្នាំ ២០០១

(តទៅទំព័រទី ៤)

## បទវិចារណកថា

(តពីទំព័រទី ១)

ដោយមិនគិតពីភេទ អាយុ ជនជាតិ ពណ៌សម្បុរអ្វីឡើយ។ល។

នៅពេលដែលត្រូវបានសាកសួរ ស្ត្រីភាគច្រើន បានបញ្ចេញឲ្យដឹងនូវបំណងប្រាថ្នា ចង់ដឹង ហើយនឹងចង់ចេះប្រើប្រាស់ ICT ប៉ុន្តែដូចដែលស្ត្រីដទៃទៀតនៅក្នុងតំបន់ដែរ ដោយសារតែពហុតួនាទី និងទំនួលខុសត្រូវក្នុងគ្រួសារច្រើនធូន់ធ្ងរពេក បានធ្វើឲ្យពេលវេលាលំហែកាយ និងការចូលរួមក្នុងសង្គមរបស់ស្ត្រីមានកម្រិត ព្រមទាំងរារាំងស្ត្រីពីការចូលទៅកាន់ ICT។ ស្ត្រីមានមុខរបរពីរ ឬក៏ពីរវេនក្នុង១ថ្ងៃ ។ វេនទីមួយ គឺនៅការិយាល័យ (ឬក៏ប្រកបការងារផ្សេងៗនៅក្រៅផ្ទះ) ហើយទីពីរ គឺនៅផ្ទះ ទីដែលស្ត្រីមានភារកិច្ចត្រូវមើលថែទាំកូនៗ និងចម្អិនអាហារសម្រាប់គ្រួសារ ខណៈពេលដែលបុរសសម្រាក។

ស្ត្រី នឹងពុំមានលទ្ធភាពប្រើប្រាស់ ICT ប្រសិនបើពួកគេ មិនមានចំណេះដឹងអំពីការប្រើប្រាស់ ICT ហើយក៏មិនអាចទទួលបានផលប្រយោជន៍ពីវានោះដែរ។ កង្វះខាតក្នុងការចូលទៅកាន់ ICT ដោយសារការលំបាកនានាទាក់ទងសង្គម វប្បធម៌ និងទីផ្សារ បាននាំឲ្យស្ត្រីនៅឆ្ងាយពីពិភពប្រមូលផ្តុំនៃព័ត៌មាន និងចំណេះដឹង។ ការឃ្លាតឆ្ងាយនេះ បានឆ្លុះបញ្ចាំងក្នុងកម្រិតនៃការផ្តល់អំណាច និងភាពស្មើគ្នារបស់ស្ត្រី បើធៀបនឹងបុរស។

នៅពេលដែលយើងរៀបចំឲ្យមានវគ្គបណ្តុះបណ្តាល ICT មានស្ត្រីតែ១៦រូប ក្នុងចំណោមសិក្ខាកាម៦០រូប មានវត្តមាននៅក្នុងវគ្គបណ្តុះបណ្តាលនោះ ។ ហេតុផលគឺថា មិនសូវមានស្ត្រី ធ្វើការជាមួយ ICT ទេ។ "ភាគរយនៃនិស្សិតស្រីដែលបញ្ចប់ការសិក្សាផ្នែកទាក់ទងនឹង ICT នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ នាឆ្នាំ២០០៣-២០០៤ មានតែ១៣% និង១១% ប៉ុណ្ណោះ។ អំឡុងពេលដូចគ្នា ភាគរយនិស្សិតស្រី ដែលបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យជាតិគ្រប់គ្រង ក្នុងទីក្រុងភ្នំពេញ ក៏មានតែ ២៣%និង២៥%" ប៉ុណ្ណោះ។ ដើម្បីឆ្លើយទៅនឹងសំនួរថាហេតុអ្វីបានជាមានស្ត្រីតិចតួច ចូលរួមក្នុងICT នោះ គឺជាបញ្ហាដ៏ធំមួយ ហើយប្រហែលជាកថាខណ្ឌដែលបានលើកឡើងខាងលើ គឺជាហេតុផលសំខាន់មួយក្នុងចំណោមហេតុផលសំខាន់ផ្សេងៗទៀត។

ស្ត្រី អាចមានដំណោះស្រាយល្អប្រសើរ សម្រាប់ទំនាស់ក្នុងគ្រួសារ ឬការបំពានផ្នែកសង្គម ប្រសិនបើនាងមានលទ្ធភាពចូលទៅកាន់ព័ត៌មានស្តីពីបញ្ហាដែលទាក់ទង។ ស្ត្រីមានជំនាញម្នាក់នឹងមានកន្លែងឈរជើងយ៉ាងរឹងមាំក្នុងទីផ្សារការងារជាងស្ត្រីដទៃទៀតដែលពុំមានជំនាញ ជាពិសេសគឺក្នុងសម័យបច្ចេកវិទ្យាព័ត៌មាន ដែលចំណេះដឹង ICT គឺជាតម្រូវការចាំបាច់ក្នុងឧស្សាហកម្មការងារ។ ទាំងអស់នេះនឹងរួមចំណែកបំពេញសេចក្តីពេញចិត្តរបស់ស្ត្រីក្នុងជីវិតរស់នៅ និងការងាររបស់គេ។

ឥឡូវនេះ គេបានយល់ហើយថា ល្គឹកណាពុំមានការផ្តល់ចំណេះដឹងដល់ស្ត្រី នោះរាល់ការខិតខំជំរុញដល់ការប្រើប្រាស់ ICT ដោយស្ត្រីនៅក្នុងប្រទេសកម្ពុជាគឺមិនទាន់ពេញលេញនៅឡើយទេ។ សំខាន់ជាងនេះទៅទៀតគឺគេត្រូវបញ្ជ្រាបទស្សនៈវិស័យយេនឌ័រ ទៅក្នុងការវិភាគគោលនយោបាយ និងការអភិវឌ្ឍន៍មធ្យោបាយ ក៏ដូចជាកិច្ចអន្តរាគមន៍ផ្សេងៗ ដែលគេមិនទាន់មានការយល់ដឹងទូលំទូលាយនៅឡើយ ហើយនឹងមេរៀនជាច្រើនទៀត សម្រាប់ការអភិវឌ្ឍន៍ក៏ត្រូវការធ្វើសមាហរណកម្មពេញលេញមួយ ដោយអ្នកធ្វើគោលនយោបាយថ្នាក់ជាតិដែរ៕

សម្រាប់ឯកសារនេះជាអេឡិចត្រូនិក៖ http://women.open.org.kh/km/cambodianwomen-and-ict

## ក្រុមការងារកម្មវិធីស្ត្រី


**លោកស្រី ជឹម ម៉ាណាវី**
និពន្ធនាយក និងជានាយិកាប្រតិបត្តិ

**លោក ឆាយ សុផល**
អ្នកនិពន្ធ

**កញ្ញា កៅ ពៅលក្ខិណា**
ជំនួយការអ្នកគ្រប់គ្រងកម្មវិធីស្ត្រី

**អាន សុប៉ូលី**
អ្នកវិភាគព័ត៌មាននិង និពន្ធ

**លោក នៅ វិធូរ**
អ្នកគ្រប់គ្រងតំបន់បណ្តាញ

**លោកស្រី ប្រាក់ សុខាយុ**
អ្នកជំនួយការគម្រោង

**លោក ម៉ក់ តារា**
ជំនួយការបច្ចេកទេសទូទៅ

**លោកស្រី អៀង កូឡា**
អ្នករចនាទំព័រ

**កញ្ញា សូ ចាន់នីម**
អ្នកវាយអត្ថបទ


កម្មវិធីស្ត្រីនៃអង្គការវិទ្យាស្ថានបើកទូលាយ សូមថ្លែងអំណរគុណចំពោះមិត្តអ្នកអាន ដែលបានគាំទ្រប្រើប្រាស់វិបផតថលស្តីអំពីស្ត្រី និងព្រឹត្តិបត្រព័ត៌មានអំពីស្ត្រី។ ក្រុមការងារយើងខ្ញុំ សូមស្វាគមន៍នូវរាល់មតិយោបល់ ការរិះគន់ក្នុងន័យស្ថាបនា និងការផ្តល់ជាអត្ថបទ ឬបទសម្ភាសន៍របស់មិត្តអ្នកអាន ដែលមានខ្លឹមសារសមស្របទៅនឹងគោលបំណងរបស់កម្មវិធីស្ត្រី ដើម្បីចុះផ្សាយលើវិបផតថលស្តីអំពីស្ត្រី និងព្រឹត្តិបត្រព័ត៌មានអំពីស្ត្រី ។


ក្រសួងព័ត៌មាន
MINISTRY OF INFORMATION

ព្រឹត្តិប័ត្រព័ត៌មានអំពីស្ត្រី ទទួលបានច្បាប់អនុញ្ញាតិចេញផ្សាយពីក្រសួងព័ត៌មាន តាមលិខិតលេខ ៤៨៥ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០០៩។

## ច្បាប់ និងសិទ្ធិ

# អនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ

(តពីលេខមុន)

អនុម័តនិងបើកឱ្យចុះហត្ថលេខា ឱ្យសច្ចាប័ន និងឱ្យចូលជាសមាជិកតាមសេចក្តីសម្រេចចិត្ត លេខ ៣៤/១៨០ ចុះថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ១៩៧៩ របស់មហាសន្និបាតអង្គការសហប្រជាជាតិ ចូលជាធរមាននៅថ្ងៃទី ៣ ខែកញ្ញា ឆ្នាំ១៩៨១ ស្របតាមបទបញ្ញត្តិមាត្រា ២៧ (១)

*រដ្ឋភាគីនៃអនុសញ្ញានេះ*

កត់សំគាល់ឃើញថាធម្មនុញ្ញសហប្រជាជាតិ អះអាងជាថ្មី នូវជំនឿលើសិទ្ធិមូលដ្ឋានរបស់មនុស្ស លើសេចក្តីថ្លៃថ្នូរ និងតម្លៃមនុស្ស និងលើសិទ្ធិស្មើគ្នារវាងបុរស និងស្ត្រី។

កត់សំគាល់ឃើញថា សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស បញ្ជាក់នូវគោលការណ៍មិនរើសអើង និងបានប្រកាសថា មនុស្សគ្រប់រូបកើតមកមានសេរីភាព និងសមភាព ក្នុងផ្នែកសេចក្តីថ្លៃថ្នូរ និងសិទ្ធិ ហើយថាមនុស្សគ្រប់រូប ត្រូវទទួលបានសិទ្ធិ និងសេរីភាពទាំងអស់ដែលមានចែងក្នុងសេចក្តីប្រកាសនោះ ដោយគ្មានការប្រកាន់បែងចែកណាមួយ រួមមានការបែងចែកខាងផ្លូវភេទផង។

កត់សំគាល់ឃើញថា រដ្ឋភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស មានកាតព្វកិច្ចធានាសិទ្ធិស្មើគ្នារវាងបុរស និងស្ត្រី ក្នុងការអាស្រ័យផលសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ ពលរដ្ឋ និងនយោបាយ។ យល់ឃើញអនុសញ្ញាអន្តរជាតិដែលបានអនុម័តក្រោមកិច្ចឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ និងស្ថាប័នឯកទេសនានា ក្នុងការលើកស្ទួយសមភាពនៃសិទ្ធិរវាងបុរស និងស្ត្រី។

កត់សំគាល់ឃើញ សេចក្តីសម្រេចចិត្ត សេចក្តីប្រកាស និងអនុសាសន៍នានា ដែលបានអនុម័តដោយអង្គការសហប្រជាជាតិ និងស្ថាប័នឯកទេសនានា ក្នុងគោលបំណងលើកស្ទួយសមភាពនៃសិទ្ធិរវាងបុរស និងស្ត្រី។ មានកង្វល់ថា ទោះបីមានលិខិតុបករណ៍ទាំងនេះហើយក្តី ក៏ការរើសអើងដ៏រីករាលដាលប្រឆាំងនឹងស្ត្រីភេទ នៅតែបន្តកើតមាន។



ទិដ្ឋភាពកិច្ចប្រជុំសមាជិកគណៈកម្មការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ (NGO-CEDAW)
រូបភាពដោយៈ អង្គការវិទ្យាស្ថានបើកទូលាយ

រំលឹកឡើងវិញថា ការរើសអើងប្រឆាំងនឹងស្ត្រីភេទ រំលោភលើគោលការណ៍សមភាពនៃសិទ្ធិ និងការគោរពសេចក្តីថ្លៃថ្នូររបស់មនុស្ស ជាឧបសគ្គដល់ការចូលរួមរបស់ស្ត្រី ក្នុងលក្ខខណ្ឌស្មើភាពគ្នាជាមួយបុរសក្នុងជីវភាពនយោបាយ សង្គមកិច្ច សេដ្ឋកិច្ច និងវប្បធម៌ នៃប្រទេសរបស់ខ្លួន ធ្វើឱ្យរាំងស្ទះដល់ការរីកចម្រើននៃភាពសម្បូណ៌រុងរឿងរបស់សង្គម និងគ្រួសារ ហើយបង្កឧបសគ្គដល់ការអភិវឌ្ឍន៍ពេញលេញនៃសក្តានុភាពរបស់ស្ត្រី ក្នុងការបម្រើប្រទេសរបស់ខ្លួន និងមនុស្សជាតិ។ មានកង្វល់ថា ក្នុងស្ថានភាពក្រីក្រ ស្ត្រីភេទបានទទួលតិចបំផុតនូវម្ហូបអាហារ សេវាសុខាភិបាល ការអប់រំ ការហ្វឹកហ្វឺន និងឱកាសរកការងារធ្វើ ហើយនឹងសេចក្តីត្រូវការដទៃទៀត។

ជឿជាក់ថា ការបង្កើតប្រព័ន្ធសេដ្ឋកិច្ចអន្តរជាតិថ្មី ផ្អែកលើមូលដ្ឋានសមភាព និងយុត្តិធម៌ នឹងរួមចំណែកយ៉ាងសំខាន់ដល់ការលើកស្ទួយសមភាពរវាងបុរស និងស្ត្រី។

គូសបញ្ជាក់ថា ការលុបបំបាត់ចោលរបបអាប៉ាថេត គ្រប់ទម្រង់ពូជសាសន៍និយម ការរើសអើងពូជសាសន៍ អាណានិគមនិយម អាណានិគមនិយមបែបថ្មី ការឈ្លានពាន ការកាន់កាប់ និងជិះជាន់ដោយបរទេស និងការជ្រៀតជ្រែកក្នុងកិច្ចការផ្ទៃក្នុងរបស់រដ្ឋ គឺជាការចាំបាច់ដល់ការអាស្រ័យផលពេញលេញពីសិទ្ធិរបស់បុរស និងស្ត្រី។

អះអាងថា ការពង្រឹងសន្តិភាព និងសន្តិសុខអន្តរជាតិ ការបន្ធូរភាពតានតឹងអន្តរជាតិ សហប្រតិបត្តិការទៅវិញទៅមករវាងរដ្ឋទាំងអស់ ដោយមិនគិតដល់ប្រព័ន្ធសេដ្ឋកិច្ច និងសង្គមកិច្ចរបស់រដ្ឋទាំងនោះ ការដកហូតអាវុធជាទូទៅ និងទាំងស្រុង ជាពិសេសការដកហូតអាវុធនុយក្លេអ៊ែរ ក្រោមការត្រួតពិនិត្យហ្មត់ចត់ និងដោយប្រសិទ្ធិភាពពីអន្តរជាតិ ការអះអាងនូវគោលការណ៍យុត្តិធម៌ សមភាព និងអត្ថប្រយោជន៍ទៅវិញទៅមក ក្នុងទំនាក់ទំនងរវាងប្រទេសទាំងឡាយ និងការសម្រេចបាននូវសិទ្ធិស្វ័យសម្រេច និងឯករាជ្យភាពរបស់ប្រជាជាតិក្រោមការជិះជាន់ និងអាណានិគមបរទេស និងការកាន់កាប់ដោយបរទេស ហើយនិងការគោរពអធិបតេយ្យភាពជាតិ និងបូរណភាពទឹកដី និងលើកស្ទួយវឌ្ឍនភាព និងការអភិវឌ្ឍន៍សង្គម ហើយផលនេះនឹងរួមចំណែកដល់ការធ្វើឱ្យសម្រេចបាននូវសមភាពពេញលេញ រវាងបុរស និងស្ត្រី។ ជឿជាក់ថា ការអភិវឌ្ឍន៍យ៉ាងពេញលេញរបស់ប្រទេសមួយ សុខុមាលភាពរបស់ពិភពលោក និងបុព្វហេតុសន្តិភាព ត្រូវការឱ្យមានការចូលរួមជាអតិបរមារបស់ស្ត្រី ដោយសមភាពជាមួយបុរស នៅក្នុងវិស័យទាំងអស់។

(មានតទៅលេខក្រោយ)

សម្រាប់ឯកសារនេះជាអេឡិចត្រូនិកៈ
http://women.open.org.kh/km/cedaw_kh

## ទេពកោសល្យស្ត្រី និងបុរស

(តពីទំព័រទី ១)

ក្រុមគ្រួសាររបស់អ្នកស្រីបានពង្រីកមុខរបររបស់ខ្លួនបានកាន់តែធំជាងមុននាពេលបច្ចុប្បន្ននេះ។

កាលនៅពីកុមារភាព ដោយសារតែជីវភាពគ្រួសារខ្សត់ខ្សោយ គាត់មិនបានរៀនសូត្រជ្រៅជ្រះឡើយ។ បើទោះជាយ៉ាងនេះក្តី អ្នកស្រីឥឡូវត្រូវបានគេចាត់ទុកថាជាអាជីវករគំរូម្នាក់នៅក្នុងភូមិ។ អ្នកស្រីមានឆន្ទៈមោះមុត ខិតខំតស៊ូព្យាយាមគ្រប់បែបយ៉ាងរួមចំណែកជាមួយស្វាមី ដើម្បីធ្វើឲ្យអាជីវកម្មរបស់គ្រួសារបានរីកចម្រើន ហើយកូនៗក៏អាចបានរៀនសូត្រនឹងគេដែរ។

ក្រៅពីមុខរបរលក់គ្រឿងទេស និងលក់កាហ្វេមានបញ្ចាំងវីដេអូ ដោយរួមទាំងចិញ្ចឹមគោ ជ្រូក និងមាន់ទាផង អ្នកស្រីក៏មានទូរស័ព្ទបីបួនគ្រឿងទៀតដាក់បម្រើជាសាធារណៈ។ ការដាក់បម្រើជាសាធារណៈនេះ អ្នកស្រីអាចបង្កើនប្រាក់ចំណូលបន្ថែមបានមួយចំនួនទៀត ដែលប្រការនេះអាចធ្វើឲ្យជីវភាពរបស់គ្រួសារបានប្រសើរជាងមុនបន្តិច។



អ្នកស្រី ផាន់ណា (ឆ្វេង) លក់គ្រឿងទេស និងដាក់ទូរស័ព្ទបម្រើសាធារណៈ
រូបភាពដោយ៖ អង្គការវិទ្យាស្ថានបើកទូលាយ

ដោយសម្លឹងមើលទៅទូរដាក់ទូរស័ព្ទដែលមានបិទលេខប្រព័ន្ធផ្សេងៗគ្នា អ្នកស្រីបាននិយាយជាមួយនឹងទឹកមុខរីករាយថា "ទូរស័ព្ទពិតជាបានផ្តល់អត្ថប្រយោជន៍ច្រើនណាស់។ វាមិនត្រឹមតែជួយសម្រួលការទាក់ទងមុខរបរបានលឿនជាងមុនប៉ុណ្ណោះនោះទេ ប៉ុន្តែវាក៏អាចជួយបន្ថែមប្រាក់ចំណូលប្រចាំថ្ងៃរបស់ខ្ញុំបានខ្លះទៀតផង"។

អ្នកស្រីបានអះអាងថា ពេលគាត់ចាប់ផ្តើមដំណើរការអាជីវកម្មដំបូង ហើយដែលកាលពីពេលនោះមិនទាន់មានទូរស័ព្ទដៃ គាត់ពិតជាមានការលំបាកណាស់ក្នុងការទាក់ទងអ្នកផ្គត់ផ្គង់ទំនិញឲ្យយកទំនិញបានទាន់ពេលវេលា។

អ្នកស្រីបានបន្ថែមថា ភាគច្រើនគាត់ត្រូវទៅដឹកអីវ៉ាន់យកមកលក់ដូរដោយខ្លួនឯង ដែលខុសប្លែកពីពេលនេះ គឺគាត់គ្រាន់តែទាក់ទងអ្នកផ្គត់ផ្គង់ទំនិញតាមទូរស័ព្ទ នោះពួកគេដឹកទំនិញមកដល់ផ្ទះ គឺចំណេញទាំងពេលវេលា និងប្រាក់កាស ហើយថា ប្រព័ន្ធទូរស័ព្ទឥឡូវមានកាន់តែច្រើនហើយតម្លៃហៅចេញក៏កាន់តែថោកជាងមុន។

បច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជាមានក្រុមហ៊ុនទូរស័ព្ទចំនួន ១១ ដែលក្នុងនោះមានប្រព័ន្ធប្រើខ្សែ (ទូរស័ព្ទលើតុ) ចំនួន ២ ក្រុមហ៊ុន និងប្រព័ន្ធឥតខ្សែ (ទូរស័ព្ទដៃ) ចំនួន ៧ ក្រុមហ៊ុន និងមាន ២ ក្រុមហ៊ុនទៀតមានទាំងប្រព័ន្ធប្រើខ្សែផង និងឥតខ្សែផង។

ដោយសារតែមានក្រុមហ៊ុនទូរស័ព្ទច្រើនបែបនេះហើយ ទើបមានតម្លៃប្រកួតប្រជែងដើម្បីទាក់ទាញអ្នកប្រើប្រាស់ឲ្យបានច្រើន។

បើតាមតួលេខរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍កម្ពុជាបានឲ្យដឹងថា មានអ្នកប្រើប្រាស់ទូរស័ព្ទលើតុចំនួន ១០០.៨៨៧ នាក់ និងអ្នកប្រើប្រាស់ស៊ីមទូរស័ព្ទដៃចំនួន ៦.៨៤៧.៦៦៧ នាក់នៅទូទាំងប្រទេស។

យោងតាមប្រភពព័ត៌មានពីក្រុមហ៊ុន TELECOM CAMBODIA និងក្រុមហ៊ុន CAMINTELបានឲ្យដឹងថា តម្លៃហៅចេញតាមប្រព័ន្ធលើតុមានចំនួន ១ សេនអាមេរិកក្នុងមួយនាទីសម្រាប់ក្នុងប្រព័ន្ធ និងមានចំនួន ៣សេនអាមេរិកក្នុងមួយនាទីសម្រាប់ហៅទៅកាន់ប្រព័ន្ធទូរស័ព្ទលើតុដទៃ។

ទាក់ទងនឹងអត្រាតម្លៃហៅតាមប្រព័ន្ធទូរស័ព្ទដៃនេះ អ្នកស្រី ផាន់ណា បាននិយាយថា កាលពីមុនការហៅទូរស័ព្ទចេញក្នុងមួយនាទីមានតម្លៃលើសពី ១០ សេនដុល្លារអាមេរិក ប៉ុន្តែឥឡូវនេះ វាមានតម្លៃទាបជាង ៦ សេនអាមេរិកក្នុងមួយនាទី ហើយជួនកាលមានការផ្តល់ជូនពិសេស គឺការហៅចេញដោយតម្លៃថោកជាងនេះ ឬហៅចេញដោយមិនគិតថ្លៃទៀតក៏មាន។

អ្នកស្រី ផាន់ណា បាននិយាយដោយទឹកមុខញញឹមថា ដោយសារតែតម្លៃហៅចេញកាន់តែថោកជាងមុននេះហើយ ទើបធ្វើឲ្យអតិថិជននិយាយទូរស័ព្ទរបស់គាត់កាន់តែច្រើនដែរ ហើយគាត់ក៏បានប្រាក់ចំណូលច្រើន គឺថា "បើមានគេហៅចេញច្រើន គឺបានប្រាក់ក៏ច្រើនទៅតាមហ្នឹងដែរ"។



អ្នកស្រី ផាន់ណា និងស្វាមី ឲ្យចំណីជ្រូក
រូបភាពដោយ៖ អង្គការវិទ្យាស្ថានបើកទូលាយ

លោក ណុះ ម៉ាត់ មេភូមិកំពង់កែសក៏បានបញ្ជាក់ដែរថា ប៉ុន្មានឆ្នាំចុងក្រោយនេះ អ្នកភូមិរបស់គាត់មានទូរស័ព្ទដៃប្រើស្ទើរតែគ្រប់គ្រួសារ ហើយគ្រួសារខ្លះមានទូរស័ព្ទបួនប្រាំគ្រឿង សូម្បីតែអ្នករត់ម៉ូតូឌុប អ្នកនេសាទក៏មានទូរស័ព្ទដៃប្រើដែរ ខណៈដែលសិស្សសាលាមធ្យមសិក្សាភាគច្រើនក៏មានទូរស័ព្ទប្រើមិនតិចនាក់ទេ។

លោកមេភូមិបានលើកឡើងថា កាលពីមុន អ្នកភូមិធ្វើដំណើររាប់រយគីឡូម៉ែត្រដើម្បីជួបនិយាយគ្នា តែបច្ចុប្បន្ន ពួកគេគ្រាន់តែហៅទូរស័ព្ទភ្លាមក៏បានជួបនិយាយគ្នាភ្លាម។

ចំណែកឯអ្នកស្រី ផាន់ណាវិញ គាត់បានសុំឲ្យរាជរដ្ឋាភិបាលជួយធ្វើយ៉ាងណាឲ្យតម្លៃហៅទូរស័ព្ទចេញកាន់តែទាប ហើយធ្វើឲ្យមានភាពងាយស្រួលក្នុងការទំនាក់ទំនងឆ្លងប្រព័ន្ធមួយទៅប្រព័ន្ធមួយ ព្រោះទូរស័ព្ទពិតជាជួយសម្រួលការងារទំនាក់ទំនង និងអាចជួយរកប្រាក់ចំណូលរបស់ប្រជាជនបានដែរ"៕

សម្រាប់ឯកសារនេះជាអេឡិចត្រូនិក៖
http://women.open.org.kh/km/phone-help-business-better

## វិស័យទូរគមនាគមន៍នៅប្រទេសកម្ពុជា

### ស្ត្រីកម្ពុជាទទួលផលប្រយោជន៍ពីបច្ចេកវិទ្យាគមនាគមន៍ ព័ត៌មានវិទ្យា

ដើម្បីបានយល់ពីការងារខ្លះលើវិស័យទូរគមនាគមន៍នៅកម្ពុជា លោកស្រី ជឹម ម៉ាណារី នាយិកាប្រតិបត្តិ អង្គការវិទ្យាស្ថានបើកទូលាយបានជួប និងធ្វើកិច្ចសម្ភាសន៍ជាមួយឯកឧត្តម ម៉ូវ ចរិយា អគ្គនាយកនៃអគ្គនាយកដ្ឋាននៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍កម្ពុជា កាលពីថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១០ កន្លងទៅនេះ។

ដោយបទសម្ភាសន៍មានលក្ខណៈវែងបន្តិច យើងសូមលើកយកខ្លឹមសារមួយចំនួនមកបង្ហាញជូន ដូចក្រោមនេះ ៖

*សំនួរ ៖ ខ្ញុំសូមអនុញ្ញាតជម្រាបសួរឯកឧត្តមថា តើស្ថានភាពនៃការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍មានលក្ខណៈបែបណាហើយនៅកម្ពុជា ?*

ឯកឧត្តម ម៉ូវ ចរិយា ៖ ហេដ្ឋារចនាសម្ព័ន្ធមានការអភិវឌ្ឍន៍លើគ្រប់វិស័យ ពិសេសខាងហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ មានតាំងពីអ៊ីនធឺណិត Transaction និង Mobile network។ សេវាទាំងនេះមានសារៈសំខាន់ណាស់។ ផ្នែកមួយទៀតខាងTelecom យើងមានប្រព័ន្ធ Wire-less សម្រាប់ចូលមកប្រព័ន្ធ Internet និងទាក់ទងសំឡេងគឺសម្រាប់ទូរស័ព្ទ។ ប្រព័ន្ធទាំងនេះមានទំនាក់ទំនងគ្នា។ កាលពីមុនយើងមាន Optical Fiber តែមួយខ្សែពីបាវិតទៅខេត្តបន្ទាយមានជ័យ ឥឡូវឡើងដល់ ១៥០០០ គ.ម រាយពាសពេញផ្ទៃប្រទេស។ អ្នកដែលបានទិញស៊ីមកាតមានចំនួនជាង ៦លាននាក់ហើយ។ ចំណែកInternet រីកចំរើនខ្លាំងចាប់តាំងពីឆ្នាំ ២០០៨ មក។ ដោយមានការលោតចូលរបស់ទូរស័ព្ទប្រព័ន្ធ 3G ក្រសួងបានបើកទូលាយនៅឆ្នាំ២០០៧ ប៉ុន្តែក្រុមហ៊ុនបានចាប់ដំណើរការរបស់ខ្លួនពីឆ្នាំ២០០៨។ យើងមានដាក់ប្រព័ន្ធ Security ទប់ស្កាត់មេរោគកុំព្យូទ័រ ហើយយើងក៏មានបង្កើតផតដាក់នៅក្នុងស្រុក និងនៅតាមព្រំដែនសម្រាប់កាត់បន្ថយចំណាយ Internet ពីក្រៅប្រទេស។



ទិដ្ឋភាពកិច្ចសម្ភាសន៍រវាង
លោកស្រី ជឹម ម៉ាណារី និងឯកឧត្តម ម៉ូវ ចរិយា
រូបភាពដោយ៖ អង្គការវិទ្យាស្ថានបើកទូលាយ

*សំនួរ៖ តើឯកឧត្តមបានធ្វើការងារទាក់ទងនឹងរចនាសម្ព័ន្ធទូរគមនាគមន៍អស់រយៈពេលប៉ុន្មានឆ្នាំហើយ ? វិស័យនោះមានការផ្លាស់ប្តូរយ៉ាងដូចម្តេចដែរចាប់តាំងពីពេលនោះមក ?*

ឯកឧត្តម ម៉ូវ ចរិយា ៖ ខ្ញុំផ្ទាល់និងក្រសួងប្រៃសណីយ៍បានរៀបចំការស្រាវជ្រាវអ៊ីនធឺណិតតាំងពីឆ្នាំ១៩៩៥ ហើយអ៊ីនធឺណិតបានចាប់ផ្តើមក្នុងឆ្នាំ១៩៩៧។ យើងឃើញថាកំណើនខុសគ្នាឆ្ងាយណាស់ គឺពីសូន្យរហូតដល់មានអតិថិជនអ្នកជួលជាវ ២៩១ពាន់នាក់រហូតដល់បច្ចុប្បន្ននេះ។ ចំណែកអ្នកប្រើប្រាស់ប្រហែល១លានទៅពីរលាននាក់ នេះជាការទស្សន៍ទាយ យើងមិនបានស្រាវជ្រាវលំអិតទេ។

*សំនួរ៖ តើមានបញ្ហាអ្វីខ្លះដែលឯកឧត្តមបានជួបប្រទះ និងកំពុងដោះស្រាយ ?*

ឯកឧត្តម ម៉ូវ ចរិយា ៖ យើងបានជួបបញ្ហាច្រើន នៅពេលអ៊ីនធឺណិតមកដល់។ មានបញ្ហា៤សំខាន់ធំៗគឺទី១បច្ចេកវិទ្យាទំនើបទាក់ទងនឹងការប្រើប្រាស់ជាភាសាអង់គ្លេស។ ទី២ សម្ភារៈនៅថ្លៃដូចជា កុំព្យូទ័រ ទាំងតម្លៃអ៊ីនធឺណិតក៏ដោយនិងទូរស័ព្ទក៏ដោយ។ ទី៣ នៅតាមបណ្តាខេត្តយើងមិនទាន់រាយបណ្តាញអ៊ីនធឺណិតបានសព្វកន្លែងទេ ឥឡូវមានក្រុមហ៊ុនមួយចំនួននាំបច្ចេកវិទ្យាចូល។ ក្រុមហ៊ុន Viettel ត្រៀមដាក់អ៊ីនធឺណិតដល់ទៅ ៣ ពាន់កន្លែង។ ទី៤ ជាបញ្ហាមួយផ្សេងទៀត គឺលើពន្ធនាំចូលរបស់កុំព្យូទ័រ និងអេឡិចត្រូនិកមិនទាន់បានចុះតម្លៃនៅឡើយទេ។ នេះជាបញ្ហាចំពោះមុខក្នុងការអភិវឌ្ឍន៍វិស័យICT។

*សំនួរ៖ តើប្រជាជនកម្ពុជារីករាយចំពោះហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ក្នុងប្រទេសកម្ពុជាយ៉ាងណាដែរ ?*

ឯកឧត្តម ម៉ូវ ចរិយា ៖ អ្នកដែលមានលទ្ធភាពប្រើប្រាស់ពិតជាសប្បាយចិត្ត ប៉ុន្តែអ្នកដែលមិនទាន់មានលទ្ធភាពប្រើប្រាស់មិនសូវសប្បាយចិត្តប៉ុន្មានទេ តែពួកគេចង់ប្រើ។ យើងបានជំរុញការបង្កើត USO (Universal Service Obligation) ឲ្យអភិវឌ្ឍដល់ជនបទ តាមគម្រោងផែនការយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល។ ប្រសិនប្រមើលមើលទៅថ្ងៃមុខ នារី និងបុរសប្រើប្រាស់ទូរគមនាគមន៍ប្រហាក់ប្រហែលគ្នា។ ឥឡូវមានក្រុមហ៊ុនច្រើនត្រូវការ website។ នេះជាឱកាសសម្រាប់និស្សិតដែលកំពុងរៀនព័ត៌មានវិទ្យាអាចមានការងារធ្វើច្រើន ពិសេសនារីៗអាចបង្កើត website ឲ្យគេ។

*សំនួរ៖ តាមគំនិតរបស់ឯកឧត្តម តើស្ត្រីកម្ពុជាសប្បាយចិត្តចំពោះការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ពន្ធទូរគមនាគមន៍យ៉ាងដូចម្តេចដែរ ?*

ឯកឧត្តម ម៉ូវ ចរិយា ៖ ដូចបានរៀបរាប់សំនួរមុនខ្លះហើយ ឥឡូវមាននិស្សិតរៀនផ្នែកព័ត៌មានវិទ្យាច្រើន ហើយមានអ៊ីមែលស្ទើរគ្រប់គ្នាសម្រាប់ធ្វើទំនាក់ទំនងគ្នា បញ្ជូនរូបភាពចាំបាច់ ឯកសារ និងលិខិតស្នាមផ្សេងៗ ហើយគេអាចកក់សំបុត្រធ្វើដំណើរតាមរយៈអ៊ីមែលផងដែរ។ ការអភិវឌ្ឍន៍នៃដំណើរការទូរគមនាគមន៍ធ្វើឲ្យមានចំណាប់អារម្មណ៍ដល់នារីៗ។ គាត់អាចគិតការសិក្សាបង្កើនចំណេះដឹង បង្កើនការងារ និងជីវភាពរបស់គាត់។ ដូច្នេះការផ្តល់ការសិក្សាដល់ពួកគេគឺសំខាន់ណាស់សម្រាប់ជាទុនមួយដ៏ធំឲ្យពួកគាត់អាចរករបរទទួលទានបាន៕

សម្រាប់ព័ត៌មានបន្ថែមសូមចូលអាននៅក្នុង៖ http://women.open.org.kh/km/interview-about-ICT

## សង្គម និងការអភិវឌ្ឍន៍

(តពីទំព័រទី ១)

ជីវភាពគ្រួសារ សហគមន៍ និងសង្គមរបស់ខ្លួនទាំងមូល។

ការងារ និងការប្រើប្រាស់ ICT នេះ ពិតជាផ្តល់ឱកាសដល់មនុស្សគ្រប់រូប និយាយដោយឡែកដល់ស្ត្រី ឲ្យពួកគេបានដឹងពីអ្វីៗដែលនៅជុំវិញខ្លួនបានយ៉ាងឆាប់រហ័ស និងបានទទួលផលប្រយោជន៍មិនខុសពីបុរសៗឡើយ។

ឯកឧត្តម ម៉ូវ ចរិយា អគ្គនាយកនៃអគ្គនាយកដ្ឋាននៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមនកម្ពុជាបានមានប្រសាសន៍ថាបច្ចុប្បន្ននេះ "ការអភិវឌ្ឍន៍នៃដំណើរការទូរគមនាគមន៍ ICT ធ្វើឲ្យមានចំណាប់អារម្មណ៍ដល់នារីៗ"។

ថ្លែងនៅក្នុងបទសម្ភាសន៍មួយជាមួយមន្ត្រីអង្គការវិទ្យាស្ថានបើកទូលាយ កាលពីថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១០ កន្លងទៅនេះ ឯកឧត្តមបានលើកឡើងថា ICT មានសារសំខាន់បំផុតសម្រាប់មនុស្សគ្រប់រូបទាំងបុរស និងស្ត្រី ហើយពួកគេមានសិទ្ធិប្រើប្រាស់ដូចៗគ្នា។

លោកបានបញ្ជាក់ថា បច្ចេកវិទ្យាព័ត៌មាន ទូរគមនាគមន៍រីកចម្រើន គឺស្ត្រីមានការងារធ្វើច្រើន ព្រោះថា សព្វថ្ងៃ អ្វីក៏ត្រូវការប្រើកុំព្យូទ័រដែរ ដូចជា ការងារគណនេយ្យ ការងារហិរញ្ញវត្ថុ និងការងារធនាគារ ក៏ដូចជានៅតាមការិយាល័យនានាត្រូវប្រើកុំព្យូទ័រ ហើយការប្រើប្រាស់នេះអាចជួយសម្រួលការងាររបស់ពួកគេច្រើនណាស់។

លោកបានលើកឧទាហរណ៍ជាក់ស្តែងពីកន្លែងការងារ ដូចជានៅធនាគារ នៅហាងអ៊ីនធឺណិត នៅតាមការិយាល័យ និងនៅតាមក្រុមហ៊ុននានាសុទ្ធតែត្រូវការអ្នកប្រើប្រាស់ ICT គឺថា ពួកគេប្រើប្រព័ន្ធកុំព្យូទ័រ ទូរស័ព្ទ អ៊ីនធឺណិត វិទ្យុ និងទូរទស្សន៍ជាដើម ហើយកន្លែងទាំងនោះសុទ្ធតែត្រូវការនារីៗទៅធ្វើការ ដូចនេះ វាជាឱកាសសម្រាប់ស្ត្រីដើម្បីទទួលបានការងារនោះ ស្មើភាពជាមួយនឹងបុរសដែរ។



កញ្ញា យ៉ែម សុភ័ក្រ កំពុងវាយអត្ថបទ និងបញ្ចូលព័ត៌មានក្នុងវិបផតថលស្តីអំពីស្ត្រី
រូបភាពដោយៈ អង្គការវិទ្យាស្ថានបើកទូលាយ

ខណៈដែលការប្រើប្រាស់ ICT ក្នុងចំណោមស្ត្រីនៅមានកម្រិតនៅឡើយ គឺមិនទាន់មានសមភាពរវាងបុរស និងស្ត្រីនោះ ឯកឧត្តម ម៉ូវ ចរិយា ក៏បានលើកទឹកចិត្តឲ្យមានការបង្រៀន និងរៀនមុខវិជ្ជា ICT នេះឲ្យកាន់តែច្រើន ដល់ស្ត្រី ព្រោះ ICT ពិតជាមានសារៈសំខាន់ណាស់សម្រាប់ជាទុនដ៏ធំមួយក្នុងការបង្កើនជីវភាព និងសម្រួលដល់ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពខ្ពស់។

កាលបើចេះមុខវិជ្ជា ICT មនុស្សអាចបំពេញការងារមិនចាំបាច់មានវត្តមាននៅក្នុងការិយាល័យក៏បាន ដែលការងារប្រភេទនេះគេហៅថា ការងារលើបណ្តាញ (Online work) បានន័យថា មនុស្សអាចធ្វើការនៅផ្ទះក៏បាន នៅហាងកាហ្វេក៏បាន រឿងសំខាន់គឺការចេះប្រើប្រាស់ប្រព័ន្ធកុំព្យូទ័រ អ៊ីនធឺណិត និងទូរស័ព្ទជាចម្បង ដើម្បីទាក់ទងគ្នា និងបញ្ជូនឯកសារ។ ដោយសារតែការងារលើបណ្តាញ នេះ ទើបមនុស្សអាចធ្វើការបានលើសពីមួយស្ថាប័ន/ក្រុមហ៊ុនក្នុងពេលតែមួយដែលអាចរកប្រាក់ចំណូលបានច្រើន។ ជាងនេះទៅទៀត មនុស្សក៏អាចសិក្សា លើបណ្តាញ (Online study) បានដែរ ដោយមិនចាំបាច់ទៅសាលាផ្ទាល់នោះទេ នេះប្រសិនបើគេចេះការងារ ICT នេះ។

ម៉្យាងទៀត ទាំងស្ថាប័នរាជរដ្ឋាភិបាល និងសង្គមស៊ីវិល ដោយរួមទាំងវិស័យឯកជនផងនាពេលបច្ចុប្បន្ននេះ ត្រូវការបង្កើតគេហទំព័រផ្ទាល់ខ្លួន ដែលជាឱកាសសម្រាប់អ្នកចេះ ICT មិនថាប្រុស ថាស្រីនោះទេ គឺឲ្យតែមានសមត្ថភាព គឺពួកគេអាចទទួលបន្ទុកការងារនេះ។ ស្ថិតក្នុងស្ថានភាពនេះ ស្ត្រីអាចមានឱកាសយ៉ាងច្រើន។

អ្នកគាំទ្រការងារស្ត្រី និងលើកស្ទួយសិទ្ធិស្ត្រី និងយេនឌ័រជាច្រើនបាននិយាយប្រហាក់ប្រហែលគ្នាថា សង្គមទាំងមូលត្រូវជួយបង្កើន និងពង្រឹងសមត្ថភាពរបស់ស្ត្រីលើវិស័យ ICT ឲ្យកាន់តែមានវិសាលភាព។ ពួកគេក៏បានជំរុញឲ្យស្ត្រីខ្លួនឯងចាប់យកមុខវិជ្ជា ICT នេះ ដើម្បីមានឱកាសមិនខុសពីបុរសៗក្នុងការរកការងារធ្វើនៅក្នុងសង្គម៕

សម្រាប់ឯកសារនេះជាអេឡិចត្រូនិកៈ http://women.open.org.kh/km/women-working-with-ICT

## ស្ត្រីនិងការប្រើប្រាស់កុំព្យូទ័រ

### ស្ត្រីមានផ្ទៃពោះគួរយល់ដឹងពីការប្រើកុំព្យូទ័រ

ស្ត្រីមានផ្ទៃពោះគួរយល់ដឹងពីការប្រើកុំព្យូទ័រ ព្រោះអាចធ្វើឲ្យប៉ះពាល់សុខភាពខ្លួនឯងផង និងទារកនៅក្នុងផ្ទៃផង។ ការអង្គុយដោយមានឥរិយាបថមិនត្រឹមត្រូវនៅពេលប្រើកុំព្យូទ័រអាចធ្វើឲ្យខ្លួនចុករួយដៃជើង ឬអស់កម្លាំងល្ហិតល្ហៃ។

តាមការដកស្រង់លទ្ធផលនៃការសិក្សាមួយពីបរទេសរបស់ទស្សនាវដ្ដីប្រជាប្រិយបានឲ្យដឹងថា ស្ត្រីមានផ្ទៃពោះគួរអង្គុយជ្រៅឲ្យពេញកៅអីខ្នងផ្អែកភ្ជាក់កៅអីកុំឲ្យពោះមូល ជាប់នឹងគែមតុ ហើយរកខ្នើយតូចៗទ្រាប់ខ្នងការពារកុំឲ្យចុករួយ។

លទ្ធផលបានផ្ដល់យោបល់ថា ពួកគេមិនគួរចំកោងខ្នង ឬអង្គុយគងអន្ទាក់ខ្លាឡើយ ហើយក្នុងករណីរួយជើង គឺអាចរកកំណល់មកកល់ជើងឲ្យខ្ពស់ បត់កែងដៃបន្តិច ដាក់ដៃលើឃីបត ដោយឲ្យកដៃសណ្ដូកត្រង់ មិនលើក ឬកាច់-កដៃចុះ។

ទស្សនាវដ្ដីក៏បានដកស្រង់លទ្ធផលទៀតថា ស្ត្រីមានគភ៌មិនត្រូវធ្វើកិច្ចការងារនៅមុខកុំព្យូទ័រជាប់ៗគ្នាយូរពេកដែរ ព្រោះការអង្គុយក្នុងឥរិយាបថដដែលៗនាំឲ្យដំណើរឈាមរត់មិនស្រួល ចុករួយសាច់ដុំ ឬរួយស្មា ខ្នង និងចង្កេះ ហើយគួរតែសម្រាកដោយអន្លើៗ គឺត្រូវក្រោកឡើងប្តូរឥរិយាបថ ១០ នាទីម្ដងក្នុងមួយម៉ោង និងរលាស់ដៃជើងតិចៗ ហើយសន្ធឹងជើងចេញបំបះចុងជើងឡើងចុះៗ ឬបង្វិល-កជើងជារង្វង់ រួមទាំងសន្ធឹងដៃធ្វើលំហាត់ផ្អែកស្មា និងកដៃផង។

លទ្ធផលបានផ្ដល់យោបល់ថា ការប្រែប្រួលអ័រម៉ូននៅពេលពពោះធ្វើឲ្យក្រពេញទឹកភ្នែកធ្វើការបានតិច ទើបបង្កឲ្យកែវភ្នែករបស់ស្ត្រីស្ងួត និងងាយផ្សាក្រហាយ ហើយថា ការប្រើកុំព្យូទ័រនៅក្នុងបន្ទប់ម៉ាស៊ីនត្រជាក់កាន់តែធ្វើឲ្យភ្នែកស្ងួតខ្លាំងឡើង។ ដូច្នេះប្រសិនបើអ្នកពាក់វ៉ែនតាមីញ៉ូបឬខន់ថេកលេន គួរតែដោះវាចេញឲ្យលឿន ដូចជាដល់ផ្ទះភ្លាមដោះចេញភ្លាម ឬប្តូរមកពាក់វ៉ែនតាជំនួសវិញ កាលណាត្រូវធ្វើកិច្ចការដោយប្រើកុំព្យូទ័រ។



ស្ត្រីមានផ្ទៃពោះកំពុងប្រើកុំព្យូទ័រ
រូបភាព៖ ទស្សនាវដ្ដី ប្រជាប្រិយ

លទ្ធផលនៃការសិក្សាក៏បានណែនាំថា ទី១ គឺតម្រូវកម្ពស់កៅអី និងអេក្រង់ឲ្យសមល្មម អេក្រង់កុំព្យូទ័រនៅត្រឹមក្រសៃភ្នែក មិនត្រូវឱន ឬងើយមុខយូរៗឡើយ និងទី២ ត្រូវរៀបចំឃីបត ម៉ៅស៍ និងឯកសារដែលត្រូវវាយបញ្ចូលក្នុងកុំព្យូទ័រឲ្យស្ថិតនៅកន្លែងដែលល្មម ដើម្បីកុំឲ្យយើងប្រើភ្នែកសម្លឹងមើល ឬរំកិលខ្លួនទើសទែងទៅមក៕

## ចំណុចគន្លឹះក្នុងការប្រើប្រាស់បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា

### ស្វែងយល់អំពីប្លង់ក្តារចុចយូនីកូដខ្មែរ

បច្ចុប្បន្ន គម្រោងកម្មវិធីកុំព្យូទ័រភាសាខ្មែរបានបង្កើតនូវប្លង់ក្តារចុច និងក្តារចុចយូនីកូដខ្មែរស្តង់ដារ ដែលមានព្យញ្ជនៈ និងស្រៈភាសាខ្មែរទាំងអស់ក្នុងប្លង់ក្តារចុចនេះ សម្រាប់ប្រើប្រាស់ក្នុងការវាយអត្ថបទ។

(សូមមើលប្លង់ក្តារចុចយូនីកូដខ្មែរនៅទំព័រទី៨)

ចំណាំ៖ ដើម្បីងាយយល់ក្នុងការអានសៀវភៅនេះ អ្នកត្រូវព្យាយាមស្វែងយល់ឈ្មោះឧបករណ៍ និងគ្រាប់ចុចទាំងអស់ជាភាសាខ្មែរ។

### ការជ្រើសរើសប្លង់ក្តារចុច

អ្នកអាចដឹងថា ក្តារចុចរបស់អ្នកកំពុងស្ថិតក្នុងភាសាអ្វីបាន ដោយមើលនៅជ្រុងខាងក្រោមផ្នែកខាងស្តាំ នៃអេក្រង់ម៉ូនីទ័រកុំព្យូទ័ររបស់អ្នក។

ប្រសិនបើឃើញអក្សរ EN នេះជាទម្រង់ខ្លីរបស់ English មានន័យថា កុំព្យូទ័ររបស់អ្នកកំពុងតែប្រើប្រាស់ក្តារចុចជាភាសាអង់គ្លេស ដូច្នេះគ្រាប់ចុចទាំងអស់ដែលអ្នកបានវាយនឹងលេចឡើងតួអក្សរជាភាសាអង់គ្លេស។

ប្រសិនបើឃើញអក្សរ CA (ចំពោះ Windows Vista នឹងបង្ហាញ KH - Khmer (Cambodia)) មានន័យថា កុំព្យូទ័ររបស់អ្នកកំពុងប្រើប្រាស់ក្តារចុចយូនីកូដខ្មែរ ដូច្នេះគ្រាប់ចុចទាំងអស់ដែលអ្នកបានវាយនឹងលេចឡើងជាតួអក្សរខ្មែរ។




កំពុងប្រើក្តារចុចអង់គ្លេស

ចំណាំ៖

- ដើម្បីវាយអក្សរខ្មែរ អ្នកត្រូវប្តូរក្តារចុចមកជាក្តារចុចខ្មែរ (CA)។
- នៅក្នុងប្លង់ក្តារចុចយូនីកូដខ្មែរបានដាក់បញ្ចូលគ្រប់ព្យញ្ជនៈ និងស្រៈដែលមាន

(តទៅទំព័រទី ៨)

(តពីទំព័រទី ៧)

ក្នុងភាសាខ្មែរ ហើយអ្នកអាចយកវាមកប្រើប្រាស់ ដើម្បីវាយអត្ថបទភាសាខ្មែរបាន ដោយគោរពតាម "ការប្រកប"។

## ការប្តូរក្តារចុចមកជាក្តារចុចយូនីកូដខ្មែរ

បញ្ញាព្រួញកណ្តុរ ចុចត្រង់អក្សរ EN នៅជ្រុងខាងក្រោមផ្នែកខាងស្តាំនៃរបារភារកិច្ច រួចជ្រើសយក CA ឬ KH (ចំពោះ Windows Vista) ដែលតំណាងឲ្យក្តារចុចយូនីកូដខ្មែរ។




ប្តូរមកជាក្តារចុចខ្មែរ

ចំពោះវីនដូវីស្តា (Windows Vista) ក្តារចុចយូនីកូដខ្មែរ សម្គាល់ដោយ KH - Khmer (Cambodia)។




កំពុងប្រើក្តារចុចអង់គ្លេសក្នុងវីនដូវីស្តា

*អ្នកអាចចុចគ្រាប់ចុចផ្លូវកាត់ដើម្បីប្តូរក្តារចុច (Alt + Shift)៖*

- មេដៃឆ្វេងចុចគ្រាប់ចុច ជំនួស (Alt)
- ម្រាមដៃឆ្វេងចុចគ្រាប់ចុច ប្តូរ (Shift)




ត្រូវបានប្តូរមកជាក្តារចុចខ្មែរក្នុងវីនដូវីស្តា

## កម្មវិធីនៃអង្គការប្រឆាំងអំពើហិង្សាក្នុងគ្រួសារ

មានកម្មវិធីចំនួន ៥ គឺកម្មវិធីទូទៅ កម្មវិធីអប់រំផ្តល់ព័ត៌មាន និងគាំទ្រ កម្មវិធីផ្សព្វផ្សាយជាសាធារណៈ កម្មវិធីប្រឆាំងការជួញដូរកុមារ និងកម្មវិធីបណ្តាញការពារសុវត្ថិភាពគ្រួសារ ខេត្តសៀមរាប និងកំពង់ចាម។ អង្គការប្រឆាំងអំពើហិង្សាក្នុងគ្រួសារផ្តល់ជូនក្រុមគោលដៅនូវសេវាកម្មពិគ្រោះពិភាក្សាផ្នែកច្បាប់ និងបញ្ជូន និងសេវាកម្មជំនាញលើស្ត្រី និងកុមារ។

### ទំនាក់ទំនងព័ត៌មាន៖

**ការិយាល័យភ្នំពេញ**
ទូរស័ព្ទលេខ ៖ ០២៣ ២១ ៩១ ៨៤

**ការិយាល័យខេត្តសៀមរាប**
ទូរស័ព្ទលេខ ៖ ០៦៣ ៩៦៤ ៩៤៨

**ការិយាល័យខេត្តកំពង់ចាម**
ទូរស័ព្ទលេខ ៖ ០១២ ៩៦៨ ១៧០ / ០១២ ៨៩៧ ០០៥




ប្លង់ក្តារចុចយូនីកូដខ្មែរ

រៀបចំ និងបោះពុម្ពផ្សាយដោយ ៖

វិទ្យាស្ថានបើកទូលាយ
Open Institute

ឧបត្ថម្ភដោយ ៖

MINISTERIO DE ASUNTOS EXTERIORES Y DE COOPERACIÓN
aecid

ផ្ទះលេខ ១៩ ផ្លូវ៣៧៨ (ទល់មុខសាលាសង្កាត់ទួលស្វាយព្រៃទី១)
ទូរស័ព្ទលេខ ៖ (៨៥៥-២៣) ២២៤ ៨២១
Website: http://open.org.kh; Email: women@open.org.kh